ការិយាល័យកណ្តាល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឲ្យដំណើរការជាផ្លូវការនូវ សេវាទូទាត់តាម ACLEDA KHQR របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ធ.អ.ក) ជាធនាគារពាណិជ្ជទីមួយក្នុងប្រទេសកម្ពុជា ដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា ថ្ងៃនេះ ធ.អ.ក បានដាក់ឲ្យដំណើរការនូវ **សេវាទូទាត់តាម KHQR**។

**សេវាទូទាត់តាម KHQR** គឺជា QR រួមតែមួយរបស់ប្រទេសកម្ពុជា ដែលគ្រឹះស្ថានធនាគារ ហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អាចប្រើប្រាស់សេវាទូទាត់ **KHQR** រួមគ្នា ដើម្បីធ្វើការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ ដោយអេស៊ីលីដាម៉ូបាល (ACLEDA Mobile) អាចស្កេន **KHQR** របស់ធនាគារផ្សេងៗ បានទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក រីឯកម្មវិធី (App) របស់ធនាគារផ្សេងៗ រួមទាំងបាគងផង ក៏អាចស្កេន **ACLEDA KHQR** បានទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកផងដែរ ចាប់ពីពេលដាក់ឲ្យដំណើរការនេះតទៅ។

**សេវាទូទាត់តាម KHQR** នេះ គឺបានផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារ ហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (Bakong App)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP